### ប្រកាសបន្ទាប់

មាត្រា ១ .- តែងតាំងឯកឧត្តម នៅ ចំនួនតារា ជាឧបការីប្រធានរដ្ឋសភា ដែលមានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

មាត្រា ២ .- ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ។

មាត្រា ៣ .- ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០០

ព្រះហស្តលេខា

នរោត្តម សីហនុ

***

# II- រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

### អនុក្រឹត្យ លេខ ៣៨ អនក្រ.បក

### ស្តីពី ការបង្កើតគណៈកម្មការ សមាហរណកម្មមន្ត្រីរាជការស៊ីវិល នៅក្នុងក្របខ័ណ្ឌថ្មី

***

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ជស.រកត. ១២៩៧-២៧៣ ចុះថ្ងៃទី០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពី គោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ

-តាមសំណូមពរចាំបាច់នៃការងារ

www.pheakdeylaw.com

## សំរេច

**មាត្រា ១ .-**

ត្រូវបានបង្កើត គណៈកម្មការសមាហរណកម្ម មន្ត្រីរាជការស៊ីវិលទៅក្នុងក្របខ័ណ្ឌថ្មី ដើម្បីផ្ទេរបញ្ចូលទៅក្នុងក្របខ័ណ្ឌថ្មីទាំងបួនប្រភេទ : ក ខ គ ឃ នូវមន្ត្រីរាជការ ស៊ីវិលទាំងឡាយ ដែលបច្ចុប្បន្នកំពុងបំពេញមុខតំណែង និងមុខងារពិតប្រាកដរបស់ក្របខ័ណ្ឌនៅក្នុងរដ្ឋបាលកណ្តាល និងតាមខេត្ត-ក្រុងទូទាំងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២ .-**

គណៈកម្មការសមាហរណកម្ម មន្ត្រីរាជការស៊ីវិលទៅក្នុងក្របខ័ណ្ឌថ្មី មានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| ១-អគ្គលេខាធិការក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល | ប្រធាន |
| ២-រដ្ឋលេខាធិការមុខងារសាធារណៈ | អនុប្រធាន |
| ៣-សមាជិកអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល | សមាជិកអចិន្ត្រៃយ៍ |
| ៤-តំណាងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ | សមាជិក |
| ៥-តំណាង ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៦-តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |
| ៧-តំណាងក្រសួង មហាផ្ទៃ | សមាជិក |
| ៨-តំណាងក្រសួងសុខាភិបាល | សមាជិក |
| ៩-តំណាងក្រសួងអប់រំយុវជន និងកីឡា | សមាជិក |
| ១០-តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១១-តំណាងក្រសួងសាធារណការ និង ដឹកជញ្ជូន | សមាជិក |
| ១២-តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១៣-តំណាងក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ | សមាជិក |
| ១៤-តំណាងក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល | សមាជិក |

**មាត្រា ៣ .-**

ប្រធានគណៈកម្មការ មានសិទ្ធិអញ្ជើញអ្នកបច្ចេកទេស ឬ តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធឯទៀត ចូលរួមប្រជុំតាមការចាំបាច់ ។

**មាត្រា ៤ .-**

គណៈកម្មការសមាហរណកម្មមន្ត្រីរាជការស៊ីវិលទៅក្នុងក្របខ័ណ្ឌថ្មី មានភារកិច្ចដូចតទៅ :

១-ពិនិត្យសិក្សាស្រាវជ្រាវ ណែនាំរៀបចំលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរាជការផ្សេងៗទៀត ក្រៅពីក្របខ័ណ្ឌមន្ត្រីរដ្ឋបាល ក្នុងករណីចាំបាច់ ជាមួយក្រសួងពាក់ព័ន្ធ

www.pheakdeylaw.com

២-សិក្សាស្រាវជ្រាវ លើកគោលការណ៍សំរាប់ការចាត់ថ្នាក់ធ្វើសមាហរណកម្មមន្ត្រីរាជការ បញ្ចូលទៅក្នុងក្របខ័ណ្ឌថ្មីជូនរាជរដ្ឋាភិបាលពិនិត្យ និងសំរេច

៣-រៀបចំកម្មវិធីសមាហរណកម្ម ដាក់អោយអនុវត្ត និងណែនាំ តាមដានការអនុវត្តនីតិវិធីនៅតាមក្រសួងស្ថាប័ននានា

៤-ធ្វើសុពលកម្មលទ្ធផលនៃការធ្វើសមាហរណកម្មមន្ត្រីរាជការស៊ីវិល បញ្ចូលទៅក្នុងក្របខ័ណ្ឌថ្មី ដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសំរេច

៥-ធ្វើសហប្រតិបត្តិការជាមួយរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងផ្ទាត់បញ្ចូលទិន្នន័យថ្មី នៃការងារសមាហរណកម្ម ទៅក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា ។

មាត្រា ៥ .-

គណៈកម្មការនេះ ស្ថិតនៅទីស្តីការគណៈរដ្ឋមន្ត្រី ក្រោមការគ្រប់គ្រងផ្ទាល់របស់ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ។

មាត្រា ៦ .-

គណៈកម្មការសមាហរណកម្មមន្ត្រីរាជការស៊ីវិលទៅក្នុងក្របខ័ណ្ឌថ្មី ធ្វើការក្រោមការដឹកនាំរបស់ប្រធានគណៈកម្មការ ហើយមានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី និង បុគ្គលិករបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ជាជំនួយការតាមការចាំបាច់ ។

មាត្រា ៧ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី និងរដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងឯកឧត្តមអស់លោក ដូចមានចែងក្នុងមាត្រា២ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

***

www.pheakdeylaw.com